**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តតាកែវ**
លេខៈ ៦៣៤ សរឯ

**សេចក្តីជូនដំណឹង**

តាកែវ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦

## ស្តីពីការរៀបចំចុះឈ្មោះអ្នកទទួលការឆ្នាំ ២០១៧

រដ្ឋបាលខេត្តតាកែវនឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ សម្រាប់ការដេញថ្លៃគម្រោងមូលនិធិឃុំ-សង្កាត់ សម្រាប់ឆ្នាំ២០១៧។ អ្នកទទួលការទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធដាក់សំណើដេញថ្លៃនៅគ្រប់គម្រោងមូលនិធិឃុំ-សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទដូចខាងក្រោមៈ

*១-ប្រភេទទី១ៈ អ្នកទទួលការសំណង់ទូទៅ(ការងារសំណង់អគារ និងការងារបេតុង.... ។ល។)*

*២-ប្រភេទទី២ៈ អ្នកទទួលការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម.......... ។ល។)*

*៣-ប្រភេទទី៣ៈ អ្នកទទួលការឯកទេស អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស (ឧទាហរណ៍ ដូចជាអណ្តូងស្នប់.......... ។ល។)*

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍ការអនុវត្តគម្រោងទាក់ទងទៅនឹងប្រភេទនីមួយៗ ដែលបានស្នើសុំយ៉ាងតិច០២គម្រោង ក្នុងអំឡុងរយៈពេល០៥ឆ្នាំចុងក្រោយនេះ។

អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ នឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេស ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជីព្រមទាំងពិនិត្យមើលគុណភាព ការងារភាពស្មោះត្រង់ លើការអនុវត្តទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ នឹងដាក់ជូនអភិបាលខេត្តដើម្បីពិនិត្យ និងសម្រេច។

អ្នកទទួលការទាំងឡាយណាដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធ នឹងការឃុបឃិត ស៊ុំគ្រលំគ្នាក្លែងបន្លំ និងអំពើពុករលួយហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធជាផ្លូវការអ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណាក្នុងការដាក់បញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអ្នកទទួលការ ដែលមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ អញ្ជើញមកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅ **ទីចាត់ការផែនការ និងវិនិយោគសាលាខេត្តតាកែវ** ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ត្រឹមវេលាម៉ោង១៧ៈ០០។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមកក៏ត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះសម្រាប់ឆ្នាំថ្មីវិញដែរ។

*សម្គាល់ៈ អាសយដ្ឋានទំនាក់ទំនង អគារគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ ទូរស័ព្ទលេខៈ០៧៧ ៨៨៣ ០៣១ ឬទាញយកពីក្នុងគេហទំព័ររបស់ គ.ជ.អ.ប។*

**អភិបាលខេត្ត**

**ឡាយ វណ្ណៈ**